# អាងហែលទឹក បន្ទាប់ពីមានករណីភ្លើងឆេះមួយ



## មានការប្រុងប្រយ័ត្នជាមុន។ ធ្វើឱ្យមានសុវត្ថិភាព។ ការពារសុខភាពរបស់អ្នក។

ផ្តល់ដំបូន្មានឱ្យអ្នកអនុវត្តតាមសេចក្តីណែនាំនានាខាងក្រោមនេះចំពោះការរក្សាអាងហែលទឹកទាំងឡាយដែលបានទទួលរកការប៉ះពាល់ដោយផ្សែង និងផេះ ឱ្យបានត្រឹមត្រូវ។

### កុំប្រើប្រាស់អាងហែលទឹក រហូតដល់បានបំពេញតាមជំហានទាំងឡាយខាងក្រោមនេះ៖

- ចូរសម្អាតកន្ត្រងឱ្យអស់កំទេចកំទី ហើយប្រើប្រាស់សំណាញ់សម្រាប់អាងហែលទឹក ដើម្បីចាប់យកកំទេចកំទីដែលអណ្តែតនៅលើផ្ទៃទឹក។
- ចូរដុសជញ្ជាំង និងបាតអាងហែលទឹកដោយប្រើប្រាស់ច្រាស ដើម្បីឱ្យរបើកសារធាតុដែលធ្វើឱ្យកខ្វក់ផ្សេងៗ ហើយបន្ទាប់មកបូមអាងហែលទឹកចេញដោយប្រើប្រាស់ម៉ាស៊ីនបូម។
- ចូរបង្ហូរទឹកបញ្ច្រាស់ថយក្រោយវិញ ដើម្បីសម្អាតតម្រង (មួយ ឬច្រើន)។ ចូរបង្ហូរកាកសំណល់ និងទឹកសម្អុយទៅក្នុង**ប្រព័ន្ធបង្ហូរទឹកសម្អុយដើម្បីឱ្យមានអនាម័យរបស់ទីក្រុង (municipal sanitary sewer) តែប៉ុណ្ណោះ**។ ប្រសិនបើមានភ្ជាប់ទៅនឹងប្រព័ន្ធអាងចាត់ចែងទឹកសម្អុយ ចូរបង្ហូរទឹកដែលហូរបញ្ច្រាស់ថយក្រោយវិញនេះទៅលើផ្ទៃដែលអាចជ្រាបទឹកបាន ដូចជាក្រួស ស្មៅ ឬទីធ្លាហាលវាល ដើម្បីឱ្យអាចជ្រាបបានដោយមិនមានសំណឹកដី។

  **ឡាប់ហាមឃាត់មិនឱ្យបញ្ចេញទឹកដែលបង្ហូរបញ្ច្រាស់ថយក្រោយវិញនេះទៅក្នុងប្រព័ន្ធលូរសម្រាប់ទឹកភ្លៀង (ដូចជានៅតាមច្រកផ្លូវតូចៗ ច្រកសម្រាប់បើកបរ ផ្លូវថ្នល់ ឬប្រឡាយសម្រាប់ទឹកភ្លៀងជាដើម) ហើយនិងព្រែកនានាឡើយ។**

- ចូរពិនិត្យកម្រិត pH ហើយកែសម្រួលឱ្យកម្រិតនេះស្ថិតនៅចន្លោះពី **7.2** និង **8.0**។
- ចូរពិនិត្យកម្រិតសាធាតុក្លរ័ដែលនៅសេសសល់ (free chlorine) ហើយកែសម្រួលឱ្យកម្រិតនេះមានចំនួនយ៉ាងហោចណាស់ **2.0 ppm សម្រាប់អាងហែលទឹក និង 3.0 ppm សម្រាប់អាងទឹកក្តៅ**។
- ចូរធានាថាប្រព័ន្ធបង្ហូរទឹកឆ្លងកាត់តម្រង (recirculation system) គឺដំណើរការបានត្រឹមត្រូវ ដោយការពិនិត្យមើលសម្ពាធរបស់តម្រង និង/ឬឧបករណ៍វាស់ល្បឿនទឹកហូរ (flow meter)។
- ចូរបើកបម្រើការអាងហែលទឹកសាជាថ្មីនៅពេលដែលកម្រិត pH ស្ថិតនៅចន្លោះពី **7.2** និង **8.0** ហើយសារធាតុ free chlorine មានចំនួនយ៉ាងហោចណាស់ **2.0 ppm សម្រាប់អាងហែលទឹក និង 3.0 ppm សម្រាប់អាងទឹកក្តៅ** តែប៉ុណ្ណោះ។

### ការព័ទ្ធរបងសម្រាប់អាងហែលទឹក

**របាំងជុំវិញអាងហែលទឹក និងអាងទឹកក្តៅគឺអាចទទួលរងការខូចខាតដោយសារករណីភ្លើងឆេះបាន។ អ្នកត្រូវតែបិទបាំងអាងហែលទឹក និងអាងទឹកក្តៅដោយមានព័ទ្ធរបងការពារ ដើម្បីទប់ស្កាត់មិនឱ្យមានការលង់ទឹក របួសស្នាមនានា ឬហានិភ័យផ្សេងទៀត៖**

- របាំងជុំវិញនេះត្រូវតែមានកម្ពស់**យ៉ាងហោចណាស់ 60 អ៊ីញ** ខ្ពស់ជាងចំណុចចោត (grade)។
- ចន្លោះប្រហោងនានាគួរតែមិនធំជាងចំនួន **4 អ៊ីញ** នោះទេ ដើម្បីទប់ស្កាត់មិនឱ្យកុមារតូចៗអាចចូលទៅបាន។
- ទ្វារ និងច្រកចូលគួរតែអាចបិទ និងជាប់គន្លឹះដោយខ្លួនឯងបាន។




សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងទៅកាន់**កម្មវិធីផ្នែកទឹកសម្រាប់ការកម្សាន្ត (Recreational Waters Program)** របស់ផ្នែកបរិស្ថានសង្គម (Environmental Health Division) តាមរយៈលេខ **(626) 430-5360** ឬក៏អ៊ីម៉េល **rhealth@ph.lacounty.gov**។
(Cambodian)

COUNTY OF LOS ANGELES
Public Health

# ការសាងសង់អាងហែលទឹក និងអាងទឹកក្ដៅសាជាថ្មី

ករណីភ្លើងឆេះអាចធ្វើឱ្យខូចខាតដល់ទម្រង់របស់អាងហែលទឹក និងអាងទឹកក្ដៅបាន ដោយរួមមានស្នូក បរិវេណជុំវិញអាង ឧបករណ៍នានា និងរបាំងជុំវិញ។ បន្ទាប់ពីមានករណីភ្លើងឆេះព្រៃមួយ សូមអនុវត្តតាមការណែនាំទាំងឡាយខាងក្រោមនេះ ដើម្បីធ្វើការជួសជុល ឬសាងសង់អាងហែលទឹករបស់អ្នកសាជាថ្មី។

## អាងហែលទឹក និងអាងទឹកក្ដៅនៅតាមផ្ទះ



កម្មវិធីរបស់រដ្ឋ (ស្តេត) ផ្នែកការប្រមូលយកកំទេចកំទីចេញ (debris removal program) គឺមិនប្រមូលយកវត្ថុផ្សេងៗពីការជួសជុលអាងហែលទឹកនោះទេ។ ម្ចាស់អាងហែលទឹកគឺទទួលខុសត្រូវទៅលើការអនុញ្ញាតឱ្យធ្វើកិច្ចការផ្សេងៗ វត្ថុពីការវាយអាងទឹកចោល ហើយនិងការវាយអាងទឹកចោលនេះ ផងដែរ។

សូមទាក់ទងទៅកាន់**នាយកដ្ឋានអគារ និងផ្នែកសុវត្ថិភាព (Building and Safety Department) នៅក្នុងតំបន់**របស់អ្នក ដើម្បីដឹងអំពីតម្រូវការចាំបាច់ និងការណែនាំទាំងឡាយទាក់ទងទៅនឹងការជួសជុលទម្រង់ និង/ឬឧបករណ៍នានារបស់អាងហែលទឹក។

ចំពោះតំបន់ដែលមិនបានរួមបញ្ចូល (unincorporated areas) នៃខោនធី LA  សូមទាក់ទងទៅកាន់**ផ្នែកអគារ និងសុវត្ថិភាពរបស់នាយកដ្ឋានកិច្ចការសាធារណៈនៃខោនធី LA (LA County Department of Public Works, Building and Safety Division) តាមរយៈលេខ (626) 458-5100**។

## ការបង្ហូរទឹកឱ្យអស់ចេញពីអាងហែលទឹក

មិនណែនាំឱ្យបង្ហូរទឹកឱ្យអស់ចេញពីអាងហែលទឹកនោះទេ។ ប្រសិនបើអ្នកត្រូវតែបង្ហូរទឹកឱ្យអស់ចេញពីអាងហែលទឹកនោះ ចូរទាក់ទងទៅកាន់**ផ្នែកកិច្ចការសាធារណៈរបស់ទីក្រុងអ្នក** ដើម្បីកំណត់អំពីតម្រូវការចាំបាច់ផ្សេងៗ។

## អាងហែលទឹក និងអាងទឹកក្ដៅសាធារណៈ



អាងហែលទឹក និងអាងទឹកក្ដៅសាធារណៈទាំងអស់ដែលមានទីតាំងនៅខាងក្នុងសណ្ឋាគារ/ផ្ទះសំណាក់ អគារមានបន្ទប់ជួលច្រើន (apartment) អគារដែលមានផ្ទះជាច្រើន (condominiums) សាលារៀន ក្លឹបហាត់ប្រាណ សួនច្បាររបស់ទីក្រុង ចំណតផ្ទះចល័ត (mobile home parks) ទីកន្លែងកម្សាន្តសម្រាប់អ្នកឈប់វិស្សមកាល (resorts) អង្គការ សួនលេងទឹក (water theme parks) និងទីតាំងផ្នែកពេទ្យទាំងឡាយនោះគឺទទួលបានការអនុញ្ញាតឱ្យប្រើប្រាស់ពីផ្នែកសុខភាពបរិស្ថាន (Environmental Health Division)។

សូមទាក់ទងទៅកាន់**កម្មវិធីផ្នែកទឹកសម្រាប់ការកម្សាន្ត (Recreational Waters Program)** ដើម្បីដឹងអំពីតម្រូវការចាំបាច់ផ្សេងៗ ហើយនិងការដាក់បញ្ជូនគម្រោងនៃការសាងសង់ (construction plan) ទាក់ទងទៅនឹងការជួសជុលណាមួយដល់ទម្រង់ និងឧបករណ៍នានារបស់អាងហែលទឹក។

**ការសម្អាតបរិវេណជុំវិញអាង** - ចូរសម្អាតបរិវេណជុំវិញអាងហែលទឹក ហើយបោះចោលកំទេចកំទីទៅជាមួយនឹងសំរាម។ កុំបាញ់ទឹកលាង ឬប្រើប្រាស់ម៉ាស៊ីនផ្លុំស្លឹកឈើជ្រុះ ព្រោះកំទេចកំទីអាចហូរចូលទៅក្នុងលូរ និងហុយទៅក្នុងខ្យល់។ ដំបូង ចូរបាញ់ទឹកបន្តិចៗទៅលើបរិវេណជុំវិញអាង ដើម្បីធ្វើឱ្យធូលីដី និងផេះហុយទៅក្នុងខ្យល់ក្នុងកម្រិតតិចបំផុត។ បន្ទាប់មក ចូរប្រើប្រាស់ច្រាស ឬអំបោសរឹងមួយ ដើម្បីបោស ហើយកើបយកកំទេចកំទីនោះដាក់ចូលទៅក្នុងថង់សំរាម។ អ្នកក៏អាចប្រើប្រាស់ដងមានសំពត់សម្រាប់ជូត និងទឹក ដើម្បីជូតសម្អាតបរិវេណជុំវិញអាងនេះផងដែរ។

# ការបង្កើតកូនរបស់សត្វមូស



អាងហែលទឹក និងអាងទឹកក្ដៅដែលមិនបានរក្សាឱ្យត្រឹមត្រូវធ្វើឱ្យមានទឹកនៅទ្រឹង ដែលក្លាយជាទីកន្លែងបង្កើតកូនសម្រាប់ឱ្យសត្វមូសធ្វើការពង ហើយដែលអាចបង្កើតជា**សត្វមូសរាប់ពាន់ក្បាល**ក្នុងរយៈពេលត្រឹមតែពីរឬបីសប្ដាហ៍ប៉ុណ្ណោះ។ សត្វមូសទាំងឡាយអាចសាយភាយជំងឺកម្រិតធ្ងន់ធ្ងរផ្សេងៗ ដូចជាជំងឺដែលបង្កឡើងដោយមេរោគ West Nile និងជំងឺដែលបង្កឡើងដោយមេរោគ Zika។

ការទប់ស្កាត់មិនឱ្យមានស្ថានភាពដែលអាចឱ្យសត្វមូសបង្កើតកូនបាននោះគឺជាចំណុចសំខាន់ ដើម្បីបញ្ឈប់មិនឱ្យមានជំងឺផ្សេងៗ។ **ការរំលឹក៖** យោងទៅតាមច្បាប់ផ្នែកសុខភាព និងសុវត្ថិភាពនៃរដ្ឋ California (California Health and Safety Codes) ម្ចាស់ផ្ទះទាំងឡាយគឺមានការទទួលខុសត្រូវក្នុងការទប់ស្កាត់មិនឱ្យមាន និងការកម្ចាត់ការបង្កើតកូនរបស់សត្វមូសនៅក្នុងបរិវេណដីរបស់ពួកគេ។

**ការបង្ហូរទឹកឱ្យអស់ចេញពីអាងហែលទឹកគឺមិនមែនជាការចាំបាច់នោះទេ។** ផ្ទុយទៅវិញ ចូរប្រើប្រាស់វិធានការណ៍សម្រាប់ការទប់ស្កាត់ខាងក្រោមនេះ ដើម្បីគ្រប់គ្រងចំនួនសត្វមូសនៅក្នុងអាងហែលទឹក ឬអាងទឹកក្ដៅដែលមិនមានប្រើប្រាស់៖

1. **Mosquito dunks [ម៉ូស ស្គី ថូ ដាំង]** - គឺជាវត្ថុរឹងមានរូបរាងដូចនំដូណាត់មួយដែលអាចដាក់នៅនឹងទឹកក្នុងអាងហែលទឹក ដើម្បីសម្លាប់ដង្កូវទឹក (កូនសត្វមូស) ហើយអាចរកទិញបាននៅតាមហាងលក់ទំនិញគ្រឿងដែក ឬហាងលក់ទំនិញសម្រាប់សួនច្បារទាំងឡាយ។
2. **Mosquito fish [ម៉ូស ស្គី ថូ ហ្វីស]** - គឺជាត្រីមានទំហំតូចៗដែលស៊ីដង្កូវទឹក (កូនសត្វមូស)។ ប្រសិនបើអ្នកប្រើប្រាស់ត្រីសម្រាប់គ្រប់គ្រងសត្វមូសនេះ អ្នកមិនអាចមានសារធាតុគីមី (ដូចជាសារធាតុក្លរ [chlorine]) នៅក្នុងទឹកនោះ ឬដាក់បន្ថែមសារធាតុគីមីទៅក្នុងទឹកនោះឡើយ។

ចំពោះព័ត៌មានអំពីត្រីសម្រាប់គ្រប់គ្រងសត្វមូស ការចាត់ចែងទឹក និងជំនួយបន្ថែមទៀតនោះ សូមទាក់ទងទៅកាន់**ទីភ្នាក់ងារបំបាត់សត្វមូសនៅក្នុងតំបន់ (Mosquito Abatement District)** ជិតអ្នក។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងទៅកាន់**កម្មវិធីផ្នែកទឹកសម្រាប់ការកម្សាន្ត (Recreational Waters Program)** របស់ផ្នែកបរិស្ថានសង្គម (Environmental Health Division) តាមរយៈលេខ **(626) 430-5360** ឬក៏អ៊ីម៉ែល **rhealth@ph.lacounty.gov**។

[2/4/25] (Cambodian)

County of Los Angeles Public Health